# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..៧៥០......សហវ.ហក.ប្រក

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែតុលា ឆ្នាំ ២០១០

# ប្រកាស

## ស្តីពីការបង្កើតថវិកាផ្នែកសម្រាប់ក្រុង ស្រុក ខណ្ឌ ដែលរចនាសម្ព័ន្ធមានការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ

*********

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស /រកម/ ០១៩៦ /១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស /រកម /០៥០៨ /០១៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រម ជស /រកម /០២៩៨ /០៣ ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ ខេត្ត ក្រុង ហើយត្រូវបានកែប្រែដោយច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ .បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការជូនទៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសេចក្តីសំរេចលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាបនៃខេត្តសៀមរាប និងស្រុកបាត់ដំបងនៃខេត្តបាត់ដំបង
- បានឃើញសេចក្តីសំរេចលេខ ១២ សសរ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក
- បានឃើញប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីបទបញ្ជាថវិការបស់ខេត្ត ក្រុង
- ប្រកាសលេខ ២០៥ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីកិច្ចប្រតិបត្តិការអនុវត្តថវិកាខេត្ត ក្រុង
- តាមតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

## **សំរេច**

**ប្រការ ១ :** ត្រូវបានបង្កើតថវិកាសម្រាប់ក្រុង ស្រុក ខណ្ឌ ដែលជាថវិកាផ្នែកនៃថវិការបស់រាជធានី ខេត្តសាមី ចំពោះក្រុង ស្រុក ខណ្ឌ ដែលរចនាសម្ព័ន្ធចាត់តាំងបានបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ។

**ប្រការ ២ :** ប្រភពធនធាន និងបន្ទុកចំណាយ របស់ថវិកាក្រុង ស្រុក ខណ្ឌ ដូចបានចែងក្នុងប្រការ ១ ខាងលើ គឺជាការបែងចែកផ្ទៃក្នុងនៃសរុបថវិការបស់រាជធានី ខេត្ត សាមី តាមរយៈការធ្វើប្រតិភូកម្មពីអភិបាលរាជធានី ខេត្ត ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**ប្រការ ៣ :** អភិបាលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដូចបានចែងក្នុងប្រការ ១ ខាងលើមានភារកិច្ចចូលរួមរៀបចំ និងអនុវត្តថវិការបស់ខ្លួន ក្នុងពេលរៀបចំ និងអនុវត្តថវិការបស់រាជធានី ខេត្តសាមីតាមប្រកាសណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៤ :** ក្រោយពីបានទទួលប្រកាសថវិកាប្រចាំឆ្នាំពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលរាជធានី ខេត្ត ត្រូវចេញដីកាបែងចែកថវិកា និងផ្ទេរសិទ្ធិអាណាប័កឲ្យទៅអភិបាលក្រុង ស្រុក ខណ្ឌ ដូចបានចែងក្នុងប្រការ ១ ខាងលើ គ្រប់គ្រង និងអនុវត្តថវិការបស់ខ្លួន ហើយផ្ញើទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ ច្បាប់ និងរតនាគាររាជធានី ខេត្ត ០១ ច្បាប់ (ច្បាប់ដើម)។

**ប្រការ ៥ :** អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវណែនាំដល់រតនាគាររាជធានី ខេត្ត អោយបើកអនុគណនីរបស់ថវិការាជធានី ខេត្ត ដើម្បីកត់ត្រាតាមដានដោយឡែកការអនុវត្តថវិការបស់ក្រុង ស្រុក ខណ្ឌ ដូចបានចែងក្នុងប្រការ ១ ខាងលើ។

**ប្រការ ៦ :** ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រធានរតនាគាររាជធានី ខេត្ត ត្រូវជួយអភិបាលរាជធានី ខេត្ត និងអភិបាលក្រុង ស្រុក ខណ្ឌ ដូចបានចែងក្នុងប្រការ ១ ខាងលើ ក្នុងការរៀបចំ និងអនុវត្តថវិការបស់ខ្លួនអោយប្រព្រឹត្តទៅតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

**ប្រការ ៧ :** ឯកឧត្តមអភិបាលរាជធានី ខេត្ត លោកអភិបាលក្រុង ស្រុក ខណ្ឌ ដូចបានចែងក្នុងប្រការ ១ ខាងលើ ប្រធានរតនាគាររាជធានី ខេត្ត លោកប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត និងអស់លោកប្រធានអង្គភាពដែលមានការពាក់ព័ន្ធត្រូវអនុវត្តតាមសេចក្តីប្រកាសនេះចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១១ តទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

ចម្លងជូន
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
-ក្រសួងមហាផ្ទៃ
-ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
"ដើម្បីសហការ"
-ដូចមាត្រា ៧
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ